BUILDING CAPACITY FOR CHANGE

# សំឡេង ជម្រើស និងការសម្រេចចិត្ត




តុលា ២០១៦

ឧបត្ថម្ភដោយ៖

DCA actalliance

christian aid

Brot für die Welt

ខ្លឹមសារសៀវភៅនេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ EU, DCA/CA និង BfdW ឡើយ។

# សេចក្ដីផ្ដើម

នៅកម្ពុជា លទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចមូលដ្ឋានបានទទួលប្រយោជន៍ ពីកម្មវិធីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែកម្ពុជានៅតែប្រឈមនឹងបញ្ហាជាច្រើនមិនទាន់ដោះស្រាយបាន។ វិទ្យាស្ថានតស៊ូមតិ និង គោលនយោបាយ(API) យល់ឃើញថា ដើម្បីធានាការផ្ទេរភារកិច្ច និងការទទួលខុសត្រូវ ទៅរដ្ឋាភិបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តការងារមានប្រសិទ្ធភាព សមាជិកក្រុមប្រឹក្សាជាប់ឆ្នោត និងមន្ត្រីរាជការនៅរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ត្រូវមាន់ការចូលរួមពីសំណាក់ប្រជាពលរដ្ឋ មន្ត្រីត្រូវមានជំនាញសមស្រប សមត្ថភាពធ្វើ និងឆន្ទៈ។ ដូច្នេះ ការអនុវត្តភារកិច្ចរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិត្រូវមានប្រសិទ្ធភាព ប្រសិទ្ធផល គណនេយ្យភាព តម្លាភាព និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់សហគមន៍មូលដ្ឋាន។

កូនសៀវភៅ "សំឡេង ជម្រើស និងការសម្រេចចិត្ត" ផលិតក្នុងគោលបំណង បង្កើននូវតម្រូវការ ឬ ការទាមទាររបស់ប្រជាពលរដ្ឋឲ្យមានអភិបាលកិច្ចល្អ សម្រាប់កំណែទម្រង់ក្នុងវិស័យអាទិភាពនានារបស់រដ្ឋាភិបាល។ កូនសៀវភៅនេះ នឹងចូលរួមចំណែកគាំទ្រ គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន។

កូនសៀវភៅនេះរៀបចំចងក្រងឡើង ដោយបានដកស្រង់ចំណុចសំខាន់ៗចេញពីឯកសារសម្រាប់បណ្ដុះបណ្ដាលស្ដីពី 'សំឡេង ជម្រើស និងការសម្រេចចិត្ត' ដែលបានរៀបចំឡើង ដោយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអភិបាលកិច្ច (GRLC) របស់ក្រសួងមហាផ្ទៃ ។

API សង្ឃឹមថាកូនសៀវភៅនេះនឹងចូលរួមលើកកម្ពស់នូវចំណេះដឹង និងអំពីសិទ្ធិ និងសារៈសំខាន់នៃការចូលរួមជាសាធារណៈ និងយន្តការដែលគាំទ្រដល់ការចូលរួមជាសាធារណៈ ក្នុងក្របខ័ណ្ឌអភិបាលកិច្ចបែបប្រជាធិបតេយ្យ។

API សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ EU DCA/CA និង BfdW ដែលបានផ្ដល់ថវិកាគាំទ្រ ក្នុងការចងក្រង និងផលិតកូនសៀវភៅនេះឡើង។

# មាតិកា

**ទំព័រ**


- ☑ សិទ្ធិ និងការចូលរួមជាសាធារណៈ ២
- ☑ ហេតុអ្វីបានជាប្រជាពលរដ្ឋមិន ចូលរួម? ៤
- ☑ ហេតុអ្វីចាំបាច់ត្រូវមានការចូលរួម ជាសាធារណៈ? ៧
- ☑ យន្តការសម្រាប់ការចូលរួមជា សាធារណៈ ៨
- ☑ រដ្ឋបាលមូលដ្ឋានប្រកបដោយ គណនេយ្យភាព ១០
- ☑ ហេតុអ្វីបានជាគណនេយ្យភាព សង្គមមានសារៈសំខាន់? ១២
- ☑ ឧបករណ៍គណនេយ្យភាពសង្គម ១៤
- ☑ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុង ការលើកស្ទួយរដ្ឋាភិបាលបើកចំហ ១៨

# សិទ្ធិ និងការចូលរួមជាសាធារណៈ

ការចូលរួមជាសាធារណៈ ជាដំណើរការមួយដែលពលរដ្ឋធម្មតា ចូលរួមក្នុងដំណើរការអ្វីមួយតាមបែបស្ម័គ្រចិត្ត ឬ ជាកាតព្វកិច្ច និងចូលរួមជាបុគ្គល ឬ ចូលរួមជាក្រុម ក្នុងគោលបំណងបង្ហាញឥទ្ធិពលរបស់ខ្លួនទៅលើការ សម្រេចចិត្តនានាដែលអាចប៉ះពាល់ដល់មនុស្ស និងជីវភាពរស់នៅរបស់សហគមន៍របស់ពួកគេទាំងអស់គ្នា" ។



## រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣១: ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាអន្តរជាតិទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

មាត្រា ៣៥: ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ ។ សេចក្ដីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

## កតិកាសញ្ញា ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

(ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នក្នុងឆ្នាំ១៩៩២)

មាត្រា២៥: ដោយគ្មានការបែងចែកដូចដែលមានចែងក្នុងមាត្រា២ និងដោយគ្មានការរឹតត្បិតដែលមិនសមហេតុផលប្រជាពលរដ្ឋមានសិទ្ធិ និងមានឱកាស ៖

(ក) រួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនជ្រើសដោយសេរី ។

(ខ) បោះឆ្នោត និងឈរឈ្មោះបោះឆ្នោតនៅក្នុងការបោះឆ្នោតពិតប្រាកដតាមការកំណត់ទៀងទាត់ ជាសកលស្មើភាព និងដោយសម្ងាត់ ដែលធានាការបញ្ចេញមតិដោយសេរីពីឆន្ទៈអ្នកបោះឆ្នោត ។

(គ) ចូលបម្រើមុខងារសាធារណៈ នៅក្នុងប្រទេសរបស់ខ្លួនក្នុងលក្ខខណ្ឌដោយស្មើភាព ។

ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងរដ្ឋបាលសាធារណៈការពង្រឹងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងពង្រឹងតួនាទីក្នុងការផ្ដល់សេវាសាធារណៈគឺជាគន្លឹះក្នុងដំណើរការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។



# ហេតុអ្វីបានជាប្រជាពលរដ្ឋមិនចូលរួម?










ការសម្រេចចិត្តរបស់ខ្ញុំ
ប្រហែលគេមិនយកពេលគិតទេ

ឲ្យតែមានតំណាង
ប្រជាពលរដ្ឋចូលរួម
គ្រប់គ្រាន់ហើយ

ខ្ញុំគ្មានពេលគ្រប់គ្រាន់
សម្រាប់ចូលរួមទេ



ខ្ញុំធុញទ្រាន់នឹង
ការពិគ្រោះយោបល់

ខ្ញុំគ្មានរង
ផលប៉ះពាល់អ្វីទេ



**សំឡេង**ផ្ដោតលើជម្រើស បំណង ឬគំនិត ឬអំណាច ឬ សិទ្ធិរបស់ប្រជាពលរដ្ឋ ដែលត្រូវនាំយកទៅដាក់បញ្ចូលក្នុងការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាអ្វីមួយ។



ប្រជាពលរដ្ឋបង្ហាញសំឡេងអំពីការព្រួយបារម្ភតាមរយៈការចូលរួម ឬតាមរយៈដំណើរការលទ្ធិប្រជាធិបតេយ្យ។ ប្រជាពលរដ្ឋទាំងអស់ មិនត្រឹមតែចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោតនោះទេ ប៉ុន្តែក៏ត្រូវចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗទាំងអស់ ជាពិសេសការសម្រេចចិត្តដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

" រដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ" ដែលជាលទ្ធិប្រជាធិបតេយ្យពោរពេញទៅដោយការចូលរួម។

ប្រជាពលរដ្ឋមានសិទ្ធិចូលរួមស្ដាប់រាល់កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំសង្កាត់បាន ប៉ុន្តែពុំមានសិទ្ធិអនុម័តទេ។ *(មាត្រា៣០ កថាខណ្ឌទី១ អនុក្រឹត្យស្ដីពីការធ្វើវិមជ្ឈការអំណាចតួនាទី និង ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់)*





## ហេតុអ្វីចាំបាច់ត្រូវមានការចូលរួមជាសាធារណៈ?

ការមានសាធារណជននៅក្នុងដំណើរការសម្រេចចិត្ត នាំមកនូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ការអនុវត្តទាំងទស្សនវិទ្យា និងសីលធម៌ ព្រមទាំងការកសាងជំនឿទុកចិត្តទាំងរដ្ឋាភិបាល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

- កសាងទំនាក់ទំនង
- បំពេញតាមបទប្បញ្ញត្តិច្បាប់ និងតម្រូវការ
- ប្រកាន់ខ្ជាប់គោលការណ៍ប្រជាធិបតេយ្យ
- កំណត់ ឧបសគ្គ បញ្ហាប្រឈម និងឱកាស ទាន់ពេល
- លើកកម្ពស់ការយល់ដឹងអំពីស្ថានភាព បញ្ហា រឿងរ៉ាវ ឱកាស និងជម្រើសសម្រាប់ធ្វើការដោះស្រាយ



- ដោះស្រាយជម្លោះមានប្រសិទ្ធភាព
- កសាងសម្ព័ន្ធភាពដើម្បីឲ្យមានការគាំទ្ររឹងមាំ
- មានព័ត៌មានច្រើនដែលអាចជឿទុកចិត្តបាន
- មានទស្សនវិស័យ និងយល់ដឹងពីគ្នាទៅវិញទៅមក
- ពិភាក្សាដោយឥតគិតថ្លៃ

# យន្តការសម្រាប់ការចូលរួមជាសាធារណៈ

## យន្តការមានស្រាប់

យន្តការសម្រាប់ការចូលរួមជាសាធារណៈផ្លូវការនៅកម្ពុជារួមមាន :

- ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់
- ផែនការវិនិយោគឃុំសង្កាត់
- គណៈកម្មាធិការធ្វើផែនការ និងថវិកាឃុំ/សង្កាត់
- គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ
- កិច្ចប្រជុំភូមិ
- កិច្ចប្រជុំក្រុមប្រឹក្សាឃុំ/សង្កាត់
- វេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំ
- វេទិកាពិគ្រោះយោបល់ សាធារណៈប្រចាំឆមាស
- ការិយាល័យប្រជាពលរដ្ឋ
- ប្រអប់គណនេយ្យភាព



ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើ ឬ ធ្វើការប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវឆ្លើយតបនឹងសំណើ ឬការប្ដឹងនោះជាកំហិត។*(មាត្រា៣១ កថាខណ្ឌទី១ អនុក្រឹត្យស្ដីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់)*

មេឃុំ ចៅសង្កាត់ត្រូវជូនព័ត៌មានដល់ប្រជាពលរដ្ឋអំពីការដោះស្រាយរបស់ក្រុមប្រឹក្សាឃុំសង្កាត់។

*(មាត្រា៣១ កថាខណ្ឌទី4 អនុក្រឹត្យស្ដីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់)*



## យន្តការក្រៅផ្លូវការ

យន្តការចូលរួមបែបក្រៅផ្លូវការនេះបានអនុវត្តនៅកម្ពុជា នៅពេលប្រជាពលរដ្ឋចាប់អារម្មណ៍ ឬ ពេលមានផលប៉ះពាល់អ្វីដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ យន្តការទាំងអស់នេះមាន៖

- ការពិភាក្សាផ្សេងៗ ជាមួយមនុស្សចាស់ក្នុងភូមិ
- អន្តរាគមន៍របស់អ្នកភូមិ ក្នុងវដ្តរបស់គម្រោងទូទៅ
- កៀរគរការចូលរួមរបស់ប្រជាពលរដ្ឋឲ្យចូលរួមក្នុងកិច្ចប្រជុំសាធារណៈក្នុងទ្រង់ទ្រាយធំ



ធាតុសំខាន់នៃការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យ

១. ការជូនដំណឹងមុន

២. សកម្មក្នុងការចែករំលែកព័ត៌មានសាធារណៈ

៣. ការចែករំលែកចំណេះដឹង

៤. ផ្តោតលើតម្លៃសហគមន៍

៥. ការកំណត់ពេលវេលាសមស្រប

៦. កម្រិតនៃការចូលរួមសមស្រប

៧. ដំណើរការចូលរួម និងការឆ្លើយតបនឹងតម្រូវការ

៨. ផ្សព្វផ្សាយលទ្ធផល ឬ របាយការណ៍សង្ខេប



# រដ្ឋបាលមូលដ្ឋានប្រកបដោយគណនេយ្យភាព

ក្នុងរដ្ឋាភិបាលបែបប្រជាធិបតេយ្យ គោលការណ៍នៃគណនេយ្យភាព ចាត់ទុកថាមន្ត្រីរដ្ឋាភិបាលដែលបានជាប់ឆ្នោត ឬ តែងតាំងដោយអ្នកដែលគេបានបោះឆ្នោតឲ្យ ត្រូវមានការទទួលខុសត្រូវចំពោះ ប្រជាពលរដ្ឋ លើការសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួន។ មន្ត្រីដែលជាប់ឆ្នោត និងមន្ត្រីរាជការស៊ីវិល ត្រូវមានគណនេយ្យភាព ចំពោះសកម្មភាព និងការងាររបស់ខ្លួន។ ម៉្យាងទៀតពួកគេត្រូវមានកាតព្វកិច្ចគោរពច្បាប់ ដោយមិនរំលោភអំណាចរបស់ខ្លួន ហើយត្រូវបម្រើផលប្រយោជន៍សាធារណៈ ក្នុងបុព្វហេតុយុត្តិធមិ ប្រសិទ្ធភាព និង ប្រសិទ្ធផល ។



## អ្វីទៅជាគណនេយ្យភាព?

គណនេយ្យភាពសំដៅលើកាតព្វកិច្ចរបស់អ្នកកាន់អំណាចក្នុងការធានាខុសត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ពួកគេ(គោរពតាមនិតីវិធីនិងបទបញ្ញត្តិ) ធាតុសំខាន់របស់គណនេយ្យភាព គឺសមត្ថភាពដែលអាចឆ្លើយតបបាន និងការធ្វើអោយមានប្រសិទ្ធភាព(ប្រសិទ្ធភាព សមធមិ និងឆ្លើយតប)។

## អ្វីទៅជាគណនេយ្យភាពសង្គម?

គណនេយ្យភាពសង្គមសំដៅដល់ការផ្សារភ្ជាប់ ឬចូលរួមរបស់ប្រជាពលរដ្ឋ (និងអង្គការសង្គមស៊ីវិល) ជាមួយរាជរដ្ឋាភិបាលអោយកាន់តែមានគណនេយ្យភាព និងប្រសិទ្ធភាព។

គណនេយ្យភាពសង្គមមានគោលបំណងជួយជំរុញ និង បំពេញបន្ថែម ដោយមិនមែនជំនួសទៅលើយន្តការគណនេយ្យភាពខាងក្នុងដែលមានរួចមកហើយអោយកាន់តែប្រសើរ។ គណនេយ្យភាពសង្គមរាប់បញ្ចូលទាំងសិទ្ធ និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ។

# តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់គណនេយ្យភាពនៅមូលដ្ឋាន

- រៀបចំការប្រជុំក្រុមប្រឹក្សាជាប្រចាំ ជាមួយសាធារណជន ដោយកំណត់កាលវិភាគច្បាស់លាស់ របៀបវារៈ និងឯកសារសំខាន់ៗដើម្បីឲ្យប្រជាពលរដ្ឋបានទទួលព័ត៌មាន និងធានាចូលរួមក្នុងកិច្ចប្រជុំប្រកបដោយផ្លែផ្កា និងយ៉ាងសកម្ម

- ប្រឹក្សាយោបល់ជាមួយប្រជាពលរដ្ឋស្តីពីការរៀបចំផែនការអភិវឌ្ឍ និងការសម្រេចចិត្ត ដែលអាចប៉ះពាល់ដល់ផលប្រយោជន៍ និងការរស់នៅរបស់ប្រជាពលរដ្ឋ



- រៀបចំវេទិកាពិគ្រោះយោបល់ ដើម្បីបានស្តាប់ឮសម្លេងរបស់ប្រជាពលរដ្ឋអំពីក្តីកង្វល់ និងតម្រូវការរបស់ប្រជាពលរដ្ឋ និងចែករំលែកព័ត៌មានជាមួយប្រជាពលរដ្ឋដើម្បីប្រមូលបានការទុកចិត្តពីប្រជាពលរដ្ឋ

- លើកទឹកចិត្តប្រជាពលរដ្ឋ ឲ្យចេះស្វែងរកឯកសារសាធារណៈសំខាន់ៗពីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសុំថតចម្លង។ ប្រជាពលរដ្ឋនឹងទទួលព័ត៌មានតាមរយៈយន្តការជាច្រើនដូចជា ក្តារខៀនបិទផ្សាយព័ត៌មាន និងយន្តការផ្សេងៗទៀត។

- ចេញសេចក្តីណែនាំ និងការសម្រេចចិត្តចុងក្រោយទៅឲ្យប្រជាពលរដ្ឋ ដូចជាសេចក្តីណែនាំស្តីពីការការពារបរិស្ថាន និងធនធានធម្មជាតិនៅតាមមូលដ្ឋាន

- បង្កើត និងពង្រឹងគណៈកម្មការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ និងដោះស្រាយបញ្ហាប្រកបដោយយុត្តិធម៌ តម្លាភាព និងប្រសិទ្ធភាព។

## ហេតុអ្វីបានជាគណនេយ្យភាពសង្គមមានសារៈសំខាន់?

សារៈសំខាន់នៃគណនេយ្យភាពសង្គម គឺផ្តោតទៅចំណុចសំខាន់ ៣ យ៉ាង គឺ ធ្វើឲ្យអភិបាលកិច្ចល្អប្រសើរឡើង បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ និង ការផ្តល់សិទ្ធិអំណាច។

**អភិបាលកិច្ច**: គឺសំដៅលើគណនេយ្យភាពរបស់មន្ត្រីសាធារណៈ ជាមូលដ្ឋានគ្រឹះ របស់អភិបាលកិច្ចល្អ និងជាបុរេលក្ខខណ្ឌ សម្រាប់លទ្ធិប្រជាធិបតេយ្យដែលមានប្រសិទ្ធភាព។



យន្តការគណនេយ្យភាពសង្គម ផ្តល់ឱកាសឲ្យពលរដ្ឋសាមញ្ញ ទទួលបានព័ត៌មាន សេចក្តីត្រូវការ និងក្តីកង្វល់របស់ខ្លួន ហើយត្រូវការឲ្យមានគណនេយ្យភាព ក្នុងពេលបោះឆ្នោត។

**បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ**: ដើម្បីសម្រេចបាននូវចំណុចនេះ គឺអាស្រ័យលើការលើកកម្ពស់សេវាសាធារណៈឲ្យប្រសើរឡើង និងការរៀបចំគោលនយោបាយសាធារណៈ ដែលប្រមូលផ្តុំព័ត៌មានគ្រប់ជ្រុងជ្រោយ។

ប្រជាពលរដ្ឋក្រីក្រពឹងផ្អែកលើសេវារដ្ឋាភិបាលជាធំ តែសមត្ថភាពពួកគេនៅមានកម្រិតដើម្បីឲ្យមន្ត្រីរដ្ឋាភិបាលមានគណនេយ្យភាព ហើយពួកគេជាអ្នកទទួលបានប្រយោជន៍ច្រើនជាងគេពីគណនេយ្យភាពសង្គម។



**ការផ្តល់សិទ្ធិអំណាច**: ជាពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រ : ទោះបីជាពុំទាន់មាននិយមន័យនៃពាក្យថា ការផ្តល់សិទ្ធិអំណាច ក្នុងអត្ថន័យធំទូលំទូលាយក៏ដោយក៏ពាក្យនេះអាចយល់បានថា ជាការពង្រីកសេរីភាពនៃការបញ្ចេញសម្លេង និងសកម្មភាព។ យន្តការគណនេយ្យភាពសង្គមពិតជាផ្តល់មធ្យោបាយមួយ ក្នុងការបង្កើន និងពង្រឹងការបញ្ចេញសំឡេងរបស់ប្រជាពលរដ្ឋ/ ក្រុមដែលបាត់បង់ផលប្រយោជន៍/ ជនងាយរងគ្រោះដោយបានផ្តល់នូវព័ត៌មានវិភាគចាំបាច់ស្តីពី សិទ្ធិ និងអភ័យឯកសិទ្ធិ និងបានស្វែងរកមតិយោបល់កែលម្អជាប្រព័ន្ធពីប្រជាពលរដ្ឋក្រីក្រ។



ដោយសារសំឡេងរបស់ប្រជាពលរដ្ឋមានភាពរឹងមាំ និងកើនឡើង ទើបប្រជាពលរដ្ឋក្រីក្រកាន់តែមានសិទ្ធិ និងអំណាចក្នុងការសម្រេចចិត្ត ហើយប្រជាពលរដ្ឋក្រីក្រក៏កាន់តែមានឱកាសទទួលបានការឆ្លើយតបកាន់តែច្រើន និងប្រសើរពីស្ថាប័នរដ្ឋាភិបាលដែរ ជាពិសេសតម្រូវការអាទិភាពជាក់ស្តែង។



គោលការណ៍នៃការអភិវឌ្ឍបែបប្រជាធិបតេយ្យ តម្រូវឲ្យក្រុមប្រឹក្សាជាប់ឆ្នោត នៅតាមរដ្ឋបាលមូលដ្ឋានឆ្លើយតប និងមានគណនេយ្យភាពចំពោះសហគមន៍មូលដ្ឋាន។ មាត្រា ២៣ ២៧ ៦៤ និង ៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ និងមាត្រា ៣៨ ៤១ ៤៣ ៦៨ និង១៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាគោលការណ៍មូលដ្ឋានគ្រឹះ ដើម្បីលើកកម្ពស់ការប្រឹក្សាយោបល់ជាមួយសាធារណជន។ **សិទ្ធិទទួលបានព័ត៌មាន** ជាកត្តាមួយដ៏សំខាន់ ដើម្បីធានាសម្រេចគោលដៅនៃគណនេយ្យភាពនៅមូលដ្ឋាន។

# ឧបករណ៍គណនេយ្យភាពសង្គម

ឧបករណ៍គណនេយ្យភាពសង្គម ជាយន្តការមួយដ៏សំខាន់ សម្រាប់ធានាធ្វើឲ្យអភិបាលកិច្ចកាន់តែប្រសើរ បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ និងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ។ បទពិសោធន៍ជាក់ស្តែងបានបង្ហាញថា ការសម្រេចគោលដៅគណនេយ្យភាពសង្គម អាចធានាបានតាមរយៈកិច្ចប្រឹងប្រែងរួមគ្នា ដោយមានអង្គភាគីពាក់ព័ន្ធចូលរួម ដូចជា (រដ្ឋាភិបាល សង្គមស៊ីវិល ប្រជាពលរដ្ឋ)។ ឧបករណ៍ទាំងនោះរួមមាន ១) ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ ២)ប័ណ្ណដាក់ពិន្ទុរបស់សហគមន៍ ៣) សវនាការជាសាធារណៈ និង ៤) ធម្មនុញ្ញប្រជាពលរដ្ឋ។

**១)ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ** បង្ហាញខ្លឹមសារសំខាន់ៗក្នុងការផ្តល់សេវាសាធារណៈដូចជា សិទ្ធិទទួលបានសេវាគុណភាព ភាពជឿជាក់នៃសេវាសាធារណៈ បញ្ហាជួបប្រទះជាច្រើនដោយអ្នកប្រើប្រាស់សេវា និងការឆ្លើយតបរបស់អ្នកផ្តល់សេវាក្នុងការដោះស្រាយបញ្ហាទាំងនេះ តម្លាភាពនៃការផ្តល់សេវាដូចជាការបើកចំហនូវស្តង់ដារគុណភាពសេវា បទដ្ឋាន និងតម្លៃនៃការប្រើប្រាស់សេវា ដោយរួមបញ្ចូលទាំងការចំណាយដែលបានលាក់បាំងដូចជាសំណូក។

ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋនឹង៖

+ ជួយស្ថាប័នផ្តល់សេវាសាធារណៈឲ្យ សម្រួលដល់ការបើកចំហការពិភាក្សា និងសកម្មភាព ស្តីពីលទ្ធផលការងាររបស់ស្ថាប័នសាធារណៈ។

+ ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ឲ្យដើរតួនាទីជាអ្នកតាមដានស្ថាប័នផ្តល់សេវាសាធារណៈ និងរដ្ឋាភិបាលមូលដ្ឋាន។



+ អនុញ្ញាតឲ្យក្រសួង និងមន្ទីរផែនការនានាតម្រង់ទិសនៃការបែងចែកថវិកាឲ្យត្រូវតាមអាទិភាព និងតាមដានការអនុវត្តផងដែរ។

+ ពង្រីកមូលធនសង្គមឲ្យធំដោយប្រមូលផ្តុំសហគមន៍ឲ្យនៅជាក្រុម ក្នុងការដោះស្រាយបញ្ហា និងចែករំលែកបទពិសោធន៍ និងក្តីកង្វល់របស់ប្រជាពលរដ្ឋ។

**២)ប័ណ្ណដាក់ពិន្ទុរបស់សហគមន៍** ជាឧបករណ៍តាមដានប្រើទិន្នន័យបែបគុណវិស័យសម្រាប់តាមដានការអនុវត្តនៅមូលដ្ឋាន និងសម្រាប់វាយតម្លៃលទ្ធផលនៃការផ្តល់សេវា និងវាយតម្លៃអង្គភាពរដ្ឋបាលរបស់រដ្ឋផងដែរ។ ដំណើរការប័ណ្ណដាក់ពិន្ទុរបស់សហគមន៍(CSC)ជាដំណើរការដែលរួមបញ្ចូលទាំងការធ្វើសវនកម្មសង្គម ការតាមដានរបស់សហគមន៍ និងប័ណ្ណដាក់ពិន្ទុរបស់សហគមន៍។



ប័ណ្ណដាក់ពិន្ទុរបស់សហគមន៍ជាឧបករណ៍មួយប្រើដើម្បីធានាឲ្យមានគណនេយ្យភាពសង្គម និងការឆ្លើយតបពីអ្នកផ្តល់សេវា។ ដោយសារមានកិច្ចប្រជុំទល់មុខគ្នារវាងអ្នកផ្តល់សេវា និងសហគមន៍ ទើបមានការផ្តល់មតិកែលម្អបានលឿន ហើយឧបករណ៍នេះជាដំណើរការរឹងមាំមួយ ក្នុងការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ។



**៣)សវនាការជាសាធារណៈ** សវនាការជាសាធារណៈជាកិច្ចប្រជុំផ្លូវការដែលមន្ត្រីមូលដ្ឋានមានបំណងស្វែងយល់ និងស្វែងរកនូវគំនិត និងមតិយោបល់របស់ប្រជាពលរដ្ឋសម្រាប់យកទៅសម្រេចចិត្ត និងចាត់វិធានការសកម្មភាព ព្រោះមន្ត្រីសាធារណៈជាអ្នកសម្រេចជំនួសមុខឲ្យរដ្ឋាភិបាល។ សវនាការជាសាធារណៈអាចជាវេទិកាដែលប្រជាពលរដ្ឋជាបុគ្គល ជាក្រុម និងជាមន្ត្រីមូលដ្ឋានមកជួបជុំគ្នា ដើម្បីផ្លាស់ប្តូរព័ត៌មាន និងទស្សនៈអំពីបញ្ហាសង្គមមុនពេលសកម្មភាពនេះត្រូវបានកំណត់យក។ សវនាការជាសាធារណៈជាវិធីសាស្ត្រជំរុញការចូលរួមជាសាធារណៈថា ជាការយកចិត្តទុកដាក់រវាងប្រជាពលរដ្ឋ និងរដ្ឋបាលមូលដ្ឋានដែលជាផ្នែកដ៏សំខាន់មួយក្នុងការធានាឲ្យមានលទ្ធិប្រជាធិបតេយ្យប្រកបដោយស្ថិរភាព។



សវនាការជាសាធារណៈគឺជាការបើកចំហដល់សាធារណជនទូទៅ។ វេទិកាបែបនេះជាឧបករណ៍មួយដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋលើកឡើងអំពីការព្រួយបារម្ភរបស់ពួកគាត់នៅចំពោះមុខមន្ត្រីដែលជាប់ឆ្នោត និងមន្ត្រីរាជការហើយយន្តការបញ្ចេញមតិដ៏សំខាន់មួយ សម្រាប់មន្ត្រីដើម្បីទទួលបានការយល់ដឹងកាន់តែប្រសើរឡើងនៃបទពិសោធន៍របស់ប្រជាពលរដ្ឋ និងទស្សនៈផ្សេងៗ។ ជាទូទៅសវនាការសាធារណៈជាធាតុមួយដ៏សំខាន់ ក្នុងគំនិតផ្តួចផ្តើមសវនកម្មសង្គម។



៤) **ធម្មនុញ្ញប្រជាពលរដ្ឋ** គឺជាឯកសារសាធារណៈខ្លីមួយ ដែលផ្ដល់ព័ត៌មានសំខាន់ៗអំពីសេវាដែលផ្ដល់ដោយទីភ្នាក់ងារសាធារណៈ។ ធម្មនុញ្ញនេះពន្យល់អំពីរបៀបដែលប្រជាពលរដ្ឋអាចទទួលបានសេវា និងពន្យល់ពីនីតិវិធីនៃការប្ដឹងតវ៉ា និងធ្វើអ្វីដែលត្រឹមត្រូវ។

ធម្មនុញ្ញនេះមានគោលការណ៍ប្រាំបួន ៖

១. កំណត់ស្តង់ដារសេវា
២. បើកចំហ និងផ្ដល់ព័ត៌មានពេញលេញ
៣. ពិគ្រោះយោបល់ និងការចូលរួម
៤. លើកកម្ពស់ការផ្ដល់ឱកាសទទួលព័ត៌មាន និងជម្រើសសម្រាប់ប្រជាពលរដ្ឋ
៥. ប្រកាន់ជំហរស្មើភាព
៦. កែតម្រូវអ្វីដែលខុស ឲ្យទៅជាត្រូវ
៧. ប្រើធនធានឲ្យមានប្រសិទ្ធភាព
៨. ភាពច្នៃប្រឌិត បង្កើតថ្មី និងកែលម្អ
៩. ធ្វើការជាមួយអ្នកផ្ដល់សេវាផ្សេងទៀត។



# ការចូលរួមរបស់ប្រជាពលរដ្ឋ
# ក្នុងការលើកស្ទួយរដ្ឋាភិបាលបើកចំហ

ប្រជាពលរដ្ឋសកម្មប្រកបដោយផ្លែផ្កា មានសមត្ថភាពបញ្ចេញសំឡេង ប្រកបដោយការស្តាបនា និងជូនដំណឹងជាមុន នូវការសម្រេចចិត្តក្នុងការបញ្ចេញសំឡេង និងជម្រើស ក្នុងដំណើរការអភិបាលកិច្ចប្រជាធិបតេយ្យ។

រដ្ឋាភិបាលបើកចំហសំដៅទៅលើរដ្ឋាភិបាលមានតម្លាភាពអាចទំនាក់ទំនងបាន និងមានសមត្ថភាពឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ រដ្ឋាភិបាលតម្លាភាព សំដៅទៅលើការទទួលស្គាល់កំហុស និងទទួលយកការរិះគន់ជាសាធារណៈ។

ការលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និយាយសំដៅលើការធានាបើកចំហឲ្យកាន់តែទូលាយ និងរួមគ្នាក្នុងការសម្រេចចិត្តលើគោលនយោបាយអ្វីមួយ។ ការក្លាយជារដ្ឋាភិបាលបើកចំហ និងរដ្ឋាភិបាលបរិយាប័ណ្ណ រដ្ឋាភិបាលនឹងទទួលបានអត្ថប្រយោជន៍ច្រើន ពីសាធារណជននូវធាតុចូលផ្សេងៗ គំនិត និងការយល់ឃើញដ៏សម្បូរបែប (សំឡេង និងការសម្រេចចិត្តរបស់ប្រជាពលរដ្ឋត្រូវបានប្រើប្រាស់យ៉ាងត្រឹមត្រូវ) ដើម្បីធានាឲ្យដំណើរការរបស់គោលនយោបាយសាធារណៈកាន់តែប្រសើរ និងការផ្តល់សេវាសាធារណៈកាន់តែល្អថែមទៀត។

លក្ខខណ្ឌទាំងនេះ អាចជួយដល់រដ្ឋាភិបាលឲ្យ ៖

- ទទួលបានការទុកចិត្តពីប្រជាពលរដ្ឋច្រើនជាងមុន
- ធានាលទ្ធផលប្រសើរជាងមុនសម្រាប់ប្រជាពលរដ្ឋដែលមានចំណូលតិច
- លើកកម្ពស់ការប្រើប្រាស់សំឡេងរបស់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្ត
- ធានាសមធម៌នៃការទទួលបានសេវា និងធនធានសាធារណៈ

- រកបានដំណោះស្រាយថ្មីៗ: ការធានាឲ្យមានការចូលរួមសកម្មពីសំណាក់ប្រជាពលរដ្ឋ ក្នុងដំណើរការធ្វើគោលនយោបាយ រដ្ឋាភិបាលអាចមានលទ្ធភាពច្រើន ក្នុងការស្វែងរកនូវដំណោះស្រាយនៃបញ្ហាគោលនយោបាយ ហើយប្រជាពលរដ្ឋអាចទទួលយកគំនិតផ្តួចផ្តើមទាំងនោះទៅដោះស្រាយបញ្ហាដោយខ្លួនឯងបាន។




ក្នុងដំណើរការធ្វើគោលនយោបាយបែបបើកចំហ និងចូលរួមទាំងអស់គ្នា រដ្ឋាភិបាលបែបប្រជាធិបតេយ្យត្រូវការសាងទំនាក់ទំនងជាមួយប្រជាពលរដ្ឋ និងជាមួយតំណាង និងអ្នកពាក់ព័ន្ធ។ គេនិយមប្រើបំផុតក្នុងដំណើរការធ្វើគោលនយោបាយមាន៖ ជូនដំណឹង ពិគ្រោះយោបល់ សហការ និងការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋអ្នកតំណាង និងអ្នកពាក់ព័ន្ធ។

ជូនដំណឹង:ស្ថាប័នរដ្ឋាភិបាលត្រូវផ្តល់ព័ត៌មានប្រកបដោយតុល្យភាព និងព័ត៌មានត្រឹមត្រូវដើម្បីជួយប្រជាពលរដ្ឋឲ្យយល់អំពីបញ្ហា ជម្រើសនៃដំណោះស្រាយ និងឱកាស។



ពិគ្រោះយោបល់: ស្ថាប័នរដ្ឋាភិបាលត្រូវតែទទួល និងឆ្លើយតបទៅនឹងមតិយោបល់រិះគន់សំណើ និងពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ និងទទួលមតិយោបល់កែលម្អពីប្រជាពលរដ្ឋ និងពីតំណាងរបស់ពួកគេ។



ការរួមបញ្ចូល: ស្ថាប័នរដ្ឋាភិបាលត្រូវធ្វើការយ៉ាងជិតស្និទ្ធ និងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ និងតំណាងរបស់ប្រជាពលរដ្ឋ ក្នុងគ្រប់ដំណាក់កាលដើម្បីធានាថា រាល់ការព្រួយបារម្ភរបស់សាធារណៈ នឹងយកទៅពិចារណា និងជូនកាលអាចដោះស្រាយបាន។

ការសហការ: ស្ថាប័នរដ្ឋាភិបាលត្រូវធ្វើការក្នុងភាពជាដៃគូជាមួយប្រជាពលរដ្ឋ និងជាមួយតំណាងរបស់ប្រជាពលរដ្ឋ និងជាមួយអ្នកពាក់ព័ន្ធ ដើម្បីកំណត់អត្តសញ្ញាណ និងស្វែងយល់អំពីបញ្ហាគោលនយោបាយ និងជម្រើសនៃដំណោះស្រាយ និងការសម្រេចចិត្តដែលអាចប៉ះពាល់ដល់ជីវភាពរស់នៅរបស់មនុស្សទាំងអស់។

ផ្តល់សិទ្ធិអំណាច: ស្ថាប័នរដ្ឋាភិបាលត្រូវតាំងចិត្តដោយស្មោះ ក្នុងការផ្តល់អំណាចនៃការសម្រេចចិត្ត ឬការទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាទៅឲ្យប្រជាពលរដ្ឋ។



# វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ជាអង្គការមិនរក ប្រាក់ចំណេញ និងមិនមែនរដ្ឋាភិបាលកម្ពុជា ដែលបានបង្កើតឡើងក្នុងខែកក្កដា ឆ្នាំ២០០៣ ជាផ្នែកមួយរបស់ PACT កម្ពុជា និង បានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅខែកក្កដាឆ្នាំ ២០០៧ និងបានក្លាយជាអង្គការឯករាជ្យពេញលេញមួយនៅឆ្នាំ២០០៨។

ទស្សនវិស័យរបស់ API គឺសម្រាប់ប្រទេសកម្ពុជាមួយ ដែលបង្កើតវប្បធម៌ជាតិពោរពេញដោយសេចក្តីសុខដុម និងលទ្ធិប្រជាធិបតេយ្យប្រកបដោយចីរភាពទាំងនយោបាយ និងសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយភាពក្រីក្រ និងការពារសិទ្ធិមនុស្ស។

បេសកកម្មរបស់ API គឺដើម្បីបម្រើតម្រូវការអភិវឌ្ឍន៍សង្គម និងប្រជាធិបតេយ្យយូរអង្វែងរបស់ប្រទេសកម្ពុជា តាមរយៈការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋឲ្យមានសមត្ថភាពចងសម្ព័ន្ធទំនាក់ទំនងជាមួយរដ្ឋាភិបាលក្នុងការការពារសិទ្ធិ និងឲ្យរដ្ឋាភិបាលបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ។

API ជាស្ថាប័នមានបេសកកម្មកសាងសមត្ថភាពតស៊ូមតិមួយដែលនាំមុខគេ ធ្វើការលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មានវិមជ្ឈការ និងពិភាក្សាគោលនយោបាយ។ វិទ្យាស្ថានបានបង្កើតកេរ្តិ៍ឈ្មោះរបស់ខ្លួនតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលអំពីការតស៊ូមតិ និងការបោះពុម្ពផ្សាយឯកសារតស៊ូមតិ ទាំងជាភាសាខ្មែរ និងអង់គ្លេសដើម្បីលើកកម្ពស់ការយល់ដឹងអំពីការតស៊ូមតិ សិទ្ធិទទួលព័ត៌មាន និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ API បង្កើននូវការចូលរួមក្នុងសកម្មភាពតស៊ូមតិ និងគោលនយោបាយផ្ទាល់ដោយឧបត្ថម្ភដល់ការស្រាវជ្រាវ និងជាមជ្ឈមណ្ឌលផ្តល់យោបល់ឯករាជ្យមួយ។

API ប្តេជ្ញាធ្វើការរួមគ្នាជាមួយស្ថាប័នជាតិ និងអន្តរជាតិទាំងអស់ ដែលចែករំលែកនូវគុណតម្លៃរបស់ខ្លួនក្នុងបុព្វហេតុតស៊ូមតិ ដើម្បីឈានទៅរកការផ្លាស់ប្តូរសង្គមវិជ្ជមាន និងដោយសន្តិវិធី។ API ប្តេជ្ញាលើកតម្កើងការសម្របសម្រួលជាមួយរដ្ឋាភិបាល ប្រជាពលរដ្ឋ និងវិស័យឯកជន។

**ផលិតដោយ**

BUILDING CAPACITY
FOR CHANGE

វិទ្យាស្ថានតស៊ូមតិ
និងគោលនយោបាយ


**វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ**

Advocacy and Policy Institute

អាស័យដ្ឋាន ៖ អាគារភ្នំពេញវីឡា លេខ ១២៤ ជាន់ទី ២
បន្ទប់លេខ ២០៦ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃ ១
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ ០២៣ ២១៣ ៤៨៦ ទូរសារ ៖ ០២៣ ២១៣ ៤៨៧

អ៊ីមែល ៖ apioffice@apiinstitute.org

វ៉ិបសាយ ៖ www.apiinstitute.org